# ទុក្ខទាំង៣ នៃខ្មែរ

១. ទុក្ខទោសទណ្ឌកម្ម គ្រប់ជំនាន់ គ្រប់គ្រងជិះជាន់ ខ្មែរគ្រប់កាល
អាងអំណាចបុណ្យ ប៉ុនមហាសាល ប្រម៉ាថជាន់ក្បាល ខ្មែរគ្នាឯង។

២. បុណ្យសក្តិមាសប្រាក់ ធាក់គុណធមិ ធ្វើបាបជាន់ករ ឥតកោតក្រែង
អែបអបបរទេស មិនរអែង បង្កាត់ភ្លើងផ្សែង ដុតប្រទេស។

៣. មានបុណ្យអំណាច ដូចយក្សមា បង្កើតគ្នីគ្នា ធ្វើផ្តាស់ផ្តេស
ល្ងង់លង់អំណាច តែធ្វើចេះ បំផ្លាញប្រទេស ជាតិ ប្រជា។

៤. អាណិតតែរាស្ត្រ ដែលរងទុក្ខ រស់ពុំដែលសុខ សែនវេទនា
ទុក្ខធំគ្រាំចិត្ត ត្បិតយក្សមា ធ្វើព្យុះសង្ឃរា ពេញដែនដី។

៥. ពីមួយជំនាន់ ទៅមួយកាល ខ្មែរមិនដែលស្រាល ផុតទុក្ខភ័យ
ទុក្ខ១ គឺទុក្ខបាត់បង់ដី សម្បត្តិព្រឹកព្រៃ ពីដូនតា។

៦. ទុក្ខ២ គឺទុក្ខខ្មែរបែកបាក់ គេពាក់មុខយ័ក្ស អោយខេមរា
ប្រយុទ្ធសំលាប់ ជាតិ សាសនា បំរើមហិច្ឆតា អោយសៀម យួន។

៧. ទុក្ខ៣ គឺទុក្ខខ្មែរមិនជា នៅឆ្កួតលេលា មិនដឹងខ្លួន
វង្វេងអំណាច មិនចោលក្បួន បំរើសៀម យួន ដូចអាយ៉ង។

៨. ទុក្ខទាំង៣ នេះជាជំងឺ ធ្វើអោយខ្មែរឈឺ ហើយរាលឆ្លង
ពីមួយទៅមួយ ដូចបំណង ប្រទេសទាំងសង គេចង់បាន។

៩. បើខ្មែរពុំព្រម ភ្ញាក់អាត្មា ខ្មែរនឹងមរណា ជាក់ពុំខាន
ខ្មែរនឹងបាត់បង់ ដីភូមិដ្ឋាន ដូចសៀម យួន បានប្លន់ពីមុន។

១០.  អាណោចអាណិត គិតផងទៅ          ខ្មែរអើយកុំខ្លៅ គិតតែគុណ
សងទៅសៀម យួន ថាជាបុណ្យ          ត្រូវគិតខ្មែរមុន គុណប្រសើរ ។

១១.  ខ្មែរត្រូវចេះគិត ចេះពិចារ          ចេះយកបញ្ញា យកមកប្រើ
កុំយកចរិក ដំឡីកី          គិតថាប្រសើ ជាងចំណេះ ។

១២.  បញ្ញា ចំណេះ ចេះមានក្បួន          ប្រសើគាប់គួន មិនដែលច្រែស
មិនដូចឡីកី មកធ្វើចេះ          អួតអាងតិរិះ ចេះពីព្រៃ ។

១៣.  ខ្មែរអើយឈប់ល្ងង់ លង់ពាក្យបោក          នោះទើបទុក្ខសោក ខ្មែរប្រុសស្រី
ស្រាកស្រានរលាយ ផុតទុក្ខភ័យ          និងនាំបូរី អោយថ្កើងថ្កាន ។

១៤.  បើខ្មែរចុះខុស ចាកកំពង់          នុះខ្មែរពិតនឹង លង់មិនខាន
រលាយបាត់បង់ បូរីដ្ឋាន          ជាតិនឹងបាត់ដាន បាត់ប្រវត្តិ ។

ដោយ **សួន  សេរីរដ្ឋា**

ក្រុងឡុង ប្រទេសអង់គ្លេស ២៨ កញ្ញា ២០០៦